នស/រកត/១០២៣/៤៤៥០

# ព្រះរាជក្រឹត្យ
## ស្តីពី
## គោរមងារឧកញ៉ា

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ព្រះរាជក្រឹត្យនេះកំណត់អំពីគោលការណ៍ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការផ្តល់គោរមងារឧកញ៉ា ជាការលើកទឹកចិត្តដល់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដែលមានគុណបំណាច់ក្នុងការចូលរួមអភិវឌ្ឍ និងកសាងជាតិ ព្រមទាំងការគ្រប់គ្រងនិងការបញ្ជាប់គោរមងារឧកញ៉ា ដើម្បីធានាបាននូវសេចក្តីថ្លៃថ្នូរ ទំនៀមទម្លាប់ប្រពៃណីល្អ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

**មាត្រា២ .-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលទទួលបានគោរមងារឧកញ៉ា នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

ពាក្យសព្ទសំខាន់ៗដែលប្រើក្នុងព្រះរាជក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

- គោរមងារឧកញ៉ា សំដៅដល់ងារកិត្តិយសដែលព្រះមហាក្សត្រទ្រង់ព្រះរាជទានដោយព្រះរាជក្រឹត្យ ទៅតាមលំដាប់ថ្នាក់ ដល់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលមានគុណបំណាច់ក្នុងការចូលរួមអភិវឌ្ឍនិងកសាងជាតិ។ ។
- គោរមវន្ត សំដៅដល់រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលទទួលបានគោរមងារឧកញ៉ាដោយព្រះរាជក្រឹត្យ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងពិនិត្យនិងវាយតម្លៃលើសំណើសុំគោរមងារនិងការបញ្ចប់គោរមងារឧកញ៉ា ដែលសរសេរជាអក្សរកាត់ថា **គ.ព.ឧ.គ.** មានសមត្ថកិច្ចពិនិត្យ វាយតម្លៃ និងលើកយោបល់ជូននាយករដ្ឋមន្ត្រីលើសំណើសុំផ្តល់និងបញ្ចប់គោរមងារឧកញ៉ា។

**គ.ព.ឧ.គ.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធានប្រចាំការ |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប | សមាជិក |
| - តំណាងសមាគមឧកញ៉ាកម្ពុជា ២រូប | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានឥស្សរិយយសនិងគោរមងារ | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃ **គ.ព.ឧ.គ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

**គ.ព.ឧ.គ.** មានអគ្គនាយកដ្ឋានឥស្សរិយយសនិងគោរមងារនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាលេខាធិការដ្ឋានក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៦ .-**

ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិប្រោសព្រះរាជទានគោរមងារឧកញ៉ាដល់រូបវន្តបុគ្គលដែលមានគុណសម្បត្តិ គុណបំណាច់ និងមានស្នាដៃដ៏ធំធេងក្នុងបុព្វហេតុជាតិ សាសនា ព្រះមហាក្សត្រ។

នាយករដ្ឋមន្ត្រីតែម្នាក់គត់ មានសិទ្ធិលើកសំណើទូលថ្វាយព្រះមហាក្សត្រក្នុងការស្នើសុំគោរមងារឧកញ៉ានិងការបញ្ចប់គោរមងារឧកញ៉ា។

## ជំពូកទី៣
## លំដាប់ថ្នាក់គោរមងារឧកញ៉ា

**មាត្រា៧ .-**

គោរមងារឧកញ៉ាមាន៣(បី)លំដាប់ថ្នាក់ ដូចខាងក្រោម៖



គេហទំព័រ ព័ត៌មានសាធារណៈ - https://t.me/oa_channel

- លំដាប់ថ្នាក់ទី១ លោកអ្នកឧកញ៉ា
- លំដាប់ថ្នាក់ទី២ អ្នកឧកញ៉ា
- លំដាប់ថ្នាក់ទី៣ ឧកញ៉ា។

## ជំពូកទី៤
## លក្ខខណ្ឌនិងលក្ខណសម្បត្តិដែលត្រូវផ្ដល់គោរមងារឧកញ៉ា

**មាត្រា៨ .-**

គោរមងារឧកញ៉ាលំដាប់ថ្នាក់ណាមួយដូចមានចែងក្នុងមាត្រា៧នៃព្រះរាជក្រឹត្យនេះ ត្រូវផ្ដល់ជូនរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដោយផ្អែកតាមគុណបំណាច់របស់រូបវន្តបុគ្គលម្នាក់ៗនោះក្នុងការចូលរួមអភិវឌ្ឍនិងកសាងជាតិ។

គុណបំណាច់ក្នុងការចូលរួមអភិវឌ្ឍនិងកសាងជាតិមានជាអាទិ៍ ការផ្ដល់អំណោយជាថវិកា ការចូលរួមបរិច្ចាគធនធានទ្រព្យសម្បត្តិ សម្ភារៈបរិក្ខានានាជូនរដ្ឋ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានាដែលក្នុងនោះមានដូចជា ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ ប្រព័ន្ធធារាសាស្ត្រ វត្តអារាម អគារសាធារណៈជាដើម របកគំហើញនូវបច្ចេកវិទ្យាថ្មីៗណាមួយ ឬស្នាដៃពិសេសដែលមានអត្ថប្រយោជន៍សម្រាប់សង្គមជាតិ។

ទំហំទឹកប្រាក់នៃអំណោយជាថវិកា តម្លៃសរុបនៃការផ្ដល់អំណោយ របកគំហើញនូវបច្ចេកវិទ្យាថ្មីៗណាមួយ ឬស្នាដៃពិសេសដែលត្រូវផ្ដល់ជូនគោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ណាមួយ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៩ .-**

ក្រៅពីលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៨នៃព្រះរាជក្រឹត្យនេះ រូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរដែលត្រូវផ្ដល់គោរមងារឧកញ៉ា ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានប្រវត្តិរូបច្បាស់លាស់
- មានកិរិយាមារយាទល្អ
- ពុំធ្លាប់ត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ
- ប្រកបមុខរបរស្របច្បាប់។

**មាត្រា១០ .-**

គោរមងារឧកញ៉ាមានវិសមិតភាពជាមួយមុខងារជាមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិនដែលកំពុងបំពេញការងារតាមក្រសួង ស្ថាប័ននានារបស់រដ្ឋ លើកលែងតែគោរមនាមដែលមានចំណេះជំនាញពិសេសលើវិស័យណាមួយ ហើយមានការទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចជាតិឬអន្តរជាតិ។

## ជំពូកទី៥
## ការវាយតម្លៃគោរមងារឧកញ៉ា

**មាត្រា១១ .-**

គោរមងារឧកញ៉ាតាមលំដាប់ថ្នាក់ ត្រូវផ្ដល់ជូនរូបវន្តបុគ្គលដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្ដីស្នើសុំពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ផ្អែកតាមយោបល់ពិនិត្យនិងវាយតម្លៃរបស់ គ.វ.ឧ.គ. ដោយអនុលោមតាមមាត្រា៨ មាត្រា៩ និងមាត្រា១២នៃព្រះរាជក្រឹត្យនេះ។

**មាត្រា១២ .-**

គ្រប់ក្រសួង ស្ថាប័ន និងសមាគមឧកញ៉ាកម្ពុជា ដែលមានបំណងស្នើសុំគោរមងារឧកញ៉ាជូនរូបវន្តបុគ្គលដែលបានចូលរួមអភិវឌ្ឍនិងកសាងជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវពិនិត្យនិងវាយតម្លៃគុណសម្បត្តិ និងគុណបំណាច់របស់រូបវន្តបុគ្គលនោះ ផ្អែកតាមលក្ខខណ្ឌនិងលក្ខណសម្បត្តិ ដូចមានចែងក្នុងមាត្រា៨ មាត្រា៩ និងមាត្រា១១នៃព្រះរាជក្រឹត្យនេះ រួចលើកសំណើជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសុំការសម្រេចពីនាយករដ្ឋមន្ត្រី។

បែបបទនិងនីតិវិធីនៃការស្នើសុំនិងវាយតម្លៃក្នុងការផ្តល់គោរមងារឧកញ៉ា ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦

## ឯកសណ្ឋានផ្លូវការរបស់គោរមងារលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា

**មាត្រា១៣ .-**

គោរមវន្តដែលទទួលបានគោរមងារជាលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា មានឯកសណ្ឋាន សញ្ញាសក្តិ និងសញ្ញាសម្គាល់ សម្រាប់ប្រើប្រាស់ក្នុងពេលចូលរួមពិធីបុណ្យជាតិ បុណ្យប្រពៃណីជាតិ និងពិធីផ្លូវការផ្សេងៗ។

### ផ្នែកទី១

### ឯកសណ្ឋានផ្លូវការរបស់គោរមងារលោកអ្នកឧកញ៉ា

**មាត្រា១៤ .-**

ឯកសណ្ឋានផ្លូវការរបស់គោរមងារលោកអ្នកឧកញ៉ា ត្រូវបានកំណត់ដូចខាងក្រោម៖

**១-ចំពោះបុរស**

ក-អាវ៖

- អាវកុត កតាំង ដៃវែងពណ៌កាកអំពៅស្រាល ដែលមានរូបសញ្ញាសម្គាល់ឧកញ៉ា ទំហំ២,៦ សង់ទីម៉ែត្រ គុណនឹង៣,៥សង់ទីម៉ែត្រ នៅលើ កតាំងនៃចុងកអាវទាំងសងខាង ចែកខ្នងខាងក្រោមទាំងសងខាង និងមានឡេវមុខជារូបសញ្ញាសម្គាល់ស្រៈ(ឧ)ពេញតួ ពណ៌មាសផុស ទំហំ២សង់ទីម៉ែត្រ ចំនួនប្រាំគ្រាប់។ នៅលើស្មាអាវមានខ្សែរទ្វសងខាងធ្វើពីក្រណាត់ដែលនៅម្ខាងៗមានរន្ធចំនួនពីរសម្រាប់បំពាក់សក្តិលើស្មា។ អាវនេះមានហោប៉ៅកាត់លើទ្រូងខាងឆ្វេងចំនួនមួយ ហើយនិងហោប៉ៅប៉ះមានគម្របហាងស្លឹកពោធិ៍ខាងក្រោមសងខាងចោះរន្ធដាក់ឡេវរូបសញ្ញាសម្គាល់ស្រៈ(ឧ) ពេញតួទំហំ២សង់ទីម៉ែត្រ ពណ៌មាសផុស នៅចំកណ្តាល
- នៅលើស្មាអាវទាំងសងខាង មានបំពាក់សញ្ញាសក្តិលោកអ្នកឧកញ៉ា
- ចុងដៃអាវចែកទាំងសងខាងមានឡេវរូបសញ្ញាសម្គាល់ស្រៈ(ឧ)ពេញតួ ទំហំ១,៥សង់ទីម៉ែត្រ ចំនួនបួនគ្រាប់ ត្រង់ជួរគ្នាលើចុងដៃអាវ
- នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់កន្លាស់អាវ ធ្វើពីមាសផ្លាទីន១៨K។

ខ-ខោ៖

- ខោជើងវែងត្រង់ ពណ៌កាកអំពៅស្រាលដូចពណ៌អាវ
- ផ្សេរផ្សេរបង្កប់ ចង្កេះត ក្បាលខោវែងស្រួចប្រវែង៥,៥សង់ទីម៉ែត្រ ដឹបភ្ជិតខាងមុខម្ខាងមួយ និងមានហោប៉ៅចំនួនបី



តេឡេក្រាម ឯកសារមន្ត្រីរាជការ: - https://t.me/oa_channel

- ហោះប៉ៅចំហៀងពីរមានមាត់បញ្ចិត និងហោះប៉ៅកាត់ខាងក្រោយមួយនៅផ្នែកខាងស្តាំ

- ហោះប៉ៅកាត់ខាងក្រោយដេរបង្កប់មិនមានគម្រប។

គ-ខ្សែក្រវាត់៖

- ខ្សែក្រវាត់ធ្វើអំពីស្បែកពណ៌ខៀវចាស់

- ក្បាលខ្សែក្រវាត់ធ្វើអំពីលោហធាតុលង្ហិន ឬស័រិទ្ធទីតានីញ៉ូម ឬមាសផ្លាទីន១៨K ទំហំ៤,៨សង់ទីម៉ែត្រ គុណនឹង៥,៨សង់ទីម៉ែត្រ ដែលមានរូបសញ្ញាសម្គាល់ឧកញ៉ា នៅចំកណ្តាល។

ឃ-ស្បែកជើង៖

- ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ

- កែងកម្ពស់៣សង់ទីម៉ែត្រ ឬកែងរាបស្មើ និងស្រោមជើងពណ៌ខ្មៅពាក់កណ្តាលស្មងជើង។

គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារលោកអ្នកឧកញ៉ាសម្រាប់បុរស មានកំណត់ក្នុងឧបសម្ព័ន្ធទី១និងឧបសម្ព័ន្ធទី២នៃព្រះរាជក្រឹត្យនេះ។

**២-ចំពោះស្ត្រី**

ក- អាវ៖

- អាវកបើក ដៃវែងពណ៌កាកអំពៅស្រាល មានរូបសញ្ញាសម្គាល់ឧកញ៉ា ទំហំ២,៦សង់ទីម៉ែត្រ គុណនឹង៣,៥សង់ទីម៉ែត្រ នៅលើ កបើក នៃ កអាវទាំងសងខាង ឆែកខ្នងខាងក្រោមមួយចំកណ្តាល មានជីបរាងខ្លួនមកក្រោមតាមលក្ខណៈអាវស្ត្រី និងមានឡេវមុខរូបសញ្ញាសម្គាល់ស្រះ (ឱ)ពេញតួ ទំហំ២សង់ទីម៉ែត្រ ពណ៌មាសផុស ចំនួនបួនគ្រាប់។ នៅលើស្មាអាវមានខ្សែរនូសងខាងធ្វើពីក្រណាត់ ដែលនៅម្ខាងៗមានរន្ធចំនួនពីរសម្រាប់បំពាក់សក្តិលើស្មា។ អាវនេះមានហោះប៉ៅខាងមុខដេរបង្កប់ចំនួនពីរនៅខាងក្រោមខិតចំហៀងចំចង្កេះទាំងសងខាង ដែលហោះប៉ៅម្ខាងៗមានគម្របរាងស្លឹកពោធិ៍ខាងក្រោម មានឡេវរូបសញ្ញាសម្គាល់ស្រះ(ឱ)ពេញតួ ទំហំ២សង់ទីម៉ែត្រ ពណ៌មាសផុស នៅចំកណ្តាល

- នៅលើស្មាអាវទាំងសងខាង មានបំពាក់សញ្ញាសក្តិលោកអ្នកឧញ៉ា

- នៅចុងដៃអាវឆែកទាំងសងខាង មានឡេវរូបសញ្ញាសម្គាល់ស្រះ(ឱ)ពេញតួ ទំហំ១,៥សង់ទីម៉ែត្រ ចំនួនបីគ្រាប់ តម្រង់ជួរគ្នាលើចុងដៃអាវ

- នៅលើអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់កន្ទាស់អាវ ធ្វើពីមាសផ្លាទីន១៨K។

ខ-សំពត់បត់៖

- សំពត់បត់ពណ៌កាកអំពៅស្រាល

- សម្រុងត្រឹមភ្នែកគោរ សម្រាប់ប្រើជាមួយអាវ កបើក ដៃវែង។

គ-ស្បែកជើង៖

- ស្បែកជើងកែងចោត កខ្លី

- កែងកម្ពស់៥សង់ទីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងស្រោមជើងកខ្លី ពណ៌ខ្មៅ។

គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារលោកអ្នកឧកញ៉ាសម្រាប់ស្ត្រី មានកំណត់ក្នុងឧបសម្ព័ន្ធទី៣និងឧបសម្ព័ន្ធទី៤នៃព្រះរាជក្រឹត្យនេះ។

# វិជ្ជកទី២

## ឯកសណ្ឋានផ្លូវការរបស់គោរមងារអ្នកឧកញ៉ា

**មាត្រា១៥ .-**

ឯកសណ្ឋានផ្លូវការរបស់គោរមងារអ្នកឧកញ៉ា ត្រូវបានកំណត់ដូចខាងក្រោម៖

**១-ចំពោះបុរស**

ក-អាវ៖

- អាវកុត កតាំង ដៃវែងពណ៌កាកអំពៅស្រាល ដែលមានរូបសញ្ញាសម្គាល់ឧកញ៉ា ទំហំ២,៦ សង់ទីម៉ែត្រ គុណនឹង៣,៥សង់ទីម៉ែត្រ លើ កតាំងនៃចុងកអាវទាំងសងខាង ផែកខ្នងខាងក្រោមទាំងសងខាង និងមានឡេវមុខជារូបសញ្ញាសម្គាល់ស្រះ(ឱ)ពេញតួ ពណ៌មាសផុស ទំហំ២ សង់ទីម៉ែត្រ ចំនួនប្រាំគ្រាប់។ នៅលើស្មាអាវមានខ្សែរទូសងខាងធ្វើពីក្រណាត់ដែលនៅម្ខាងៗ មានរទូចំនួនពីរសម្រាប់បំពាក់សក្តិលើស្មា។ អាវនេះមានហោប៉ៅកាត់លើទ្រូងខាងឆ្វេងចំនួនមួយ ហើយនិងហោប៉ៅប៉ះមានគម្របរាងស្លឹកពោធិ៍ខាងក្រោមសងខាងចោះរទូដាក់ឡេវរូបសញ្ញាសម្គាល់ស្រះ(ឱ)ពេញតួ ទំហំ២សង់ទីម៉ែត្រ ពណ៌មាសផុស នៅចំកណ្តាល
- នៅលើស្មាអាវទាំងសងខាង មានបំពាក់សញ្ញាសក្តិអ្នកឧកញ៉ា
- នៅចុងដៃអាវផែកទាំងសងខាងមានឡេវរូបសញ្ញាសម្គាល់ស្រះ(ឱ)ពេញតួ ទំហំ១,៥សង់ទីម៉ែត្រ ចំនួនបួនគ្រាប់ តម្រង់ជួរគ្នាលើចុងដៃអាវ
- នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់កន្លាស់អាវ ធ្វើពីមាសផ្លាទីន១៨K។

ខ-ខោ៖

- ខោជើងវែងត្រង់ ពណ៌កាកអំពៅស្រាលដូចពណ៌អាវ
- ដេរជ្រួញបង្កប់ ចង្កេះត ក្បាលខោវែងស្រួចប្រវែង៥,៥សង់ទីម៉ែត្រ ដឹបភ្ជិខាងមុខម្ខាងមួយ និងមានហោប៉ៅចំនួនបី
- ហោប៉ៅចំហៀងពីរមានមាត់បញ្ឆិត និងហោប៉ៅកាត់ខាងក្រោយមួយនៅផ្នែកខាងស្តាំ
- ហោប៉ៅកាត់ខាងក្រោយដេរបង្កប់ មិនមានគម្រប។

គ-ខ្សែក្រវាត់៖

- ខ្សែក្រវាត់ធ្វើអំពីស្បែកពណ៌ខៀវចាស់
- ក្បាលខ្សែក្រវាត់ធ្វើអំពីលោហធាតុលង្ហិន ឬស៊ីវ៉ុទីតានីញ៉ូម ឬមាសផ្លាទីន១៨K ទំហំ៤,៨សង់ទីម៉ែត្រ គុណនឹង៥,៥សង់ទីម៉ែត្រ ដែលមានរូបសញ្ញាសម្គាល់ឧកញ៉ា នៅចំកណ្តាល។

ឃ-ស្បែកជើង៖

- ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ
- កែងកម្ពស់៣សង់ទីម៉ែត្រ ឬកែងរាបស្មើ និងស្រោមជើងពណ៌ខ្មៅ ពាក់កណ្តាលស្មងជើង។

គំរូឯកសណ្ឋានផ្លូវការរបស់គោរមនាមអ្នកឧកញ៉ាសម្រាប់បុរស មានកំណត់ក្នុងឧបសម្ព័ន្ធទី៥និងឧបសម្ព័ន្ធទី៦នៃព្រះរាជក្រឹត្យនេះ។

**២-ចំពោះស្ត្រី**

ក-អាវ៖

អាវកបើក ដៃវែងពណ៌កាកអំពៅស្រាល មានរូបសញ្ញាសម្គាល់ឧកញ៉ា ទំហំ២,៦សង់ទីម៉ែត្រ គុណនឹង៣,៥សង់ទីម៉ែត្រ លើ កបើកនៃកអាវទាំងសងខាង ផែកខ្នងខាងក្រោមមួយចំកណ្តាល



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

មានជីបរាងខ្នងមកក្រោមតាមលក្ខណៈអាវស្ត្រី និងមានឡេវមុខរូបសញ្ញាសម្គាល់ស្រះ(ឧ)ពេញតួ ទំហំ២សង់ទីម៉ែត្រ ពណ៌មាសផុស ចំនួនបួនគ្រាប់។ នៅលើស្មាអាវមានខ្សែរន្ធសងខាងធ្វើពីក្រណាត់ដែលនៅម្ខាងៗមានរន្ធចំនួនពីរសម្រាប់បំពាក់សក្តិលើស្មា។ អាវនេះមានហោប៉ៅខាងមុខដេរបង្កប់ចំនួនពីរនៅខាងក្រោមខិតចំហៀងចំចង្កេះទាំងសងខាង ដែលហោប៉ៅម្ខាងៗមានគម្របរាងស្លឹកពោធិ៍ខាងក្រោមមានឡេវរូបសញ្ញាសម្គាល់ស្រះ(ឧ)ពេញតួ ទំហំ២សង់ទីម៉ែត្រ ពណ៌មាសផុស នៅចំកណ្តាល

- នៅលើស្មាអាវទាំងសងខាង មានបំពាក់សញ្ញាសក្តិអ្នកឧញ៉ា
- នៅចុងដៃអាវផែកទាំងសងខាងមានឡេវរូបសញ្ញាសម្គាល់ស្រះ(ឧ)ពេញតួទំហំ១,៥សង់ទី ម៉ែត្រ ចំនួនបីគ្រាប់ តម្រង់ជួរគ្នាលើចុងដៃអាវ។
- នៅលើអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់កន្លាស់អាវ ធ្វើពីមាសផ្លាទីន១៨K។

ខ-សំពត់បត់៖

- សំពត់បត់ពណ៌កាកអំពៅស្រាល
- សម្រុងត្រឹមភ្នែកគោរ សម្រាប់ប្រើជាមួយអាវ កបើកដៃវែង។

គ-ស្បែកជើង៖

- ស្បែកជើងកែងចោត កខ្ចី
- កែងកម្ពស់៥សង់ទីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងស្រោមជើងកខ្ចីពណ៌ខ្មៅ។

គំរូឯកសណ្ឋានផ្លូវការរបស់គោរមន្ត្រីអ្នកឧកញ៉ាសម្រាប់ស្ត្រី មានកំណត់ក្នុងឧបសម្ព័ន្ធទី៧និងឧបសម្ព័ន្ធទី៨នៃព្រះរាជក្រឹត្យនេះ។

## ផ្នែកទី៣
## ឯកសណ្ឋានផ្លូវការរបស់គោរមងារឧកញ៉ា

**មាត្រា១៦ .–**

ឯកសណ្ឋានផ្លូវការរបស់គោរមងារឧកញ៉ា ត្រូវបានកំណត់ដូចខាងក្រោម៖

**១-ចំពោះបុរស**

ក-អាវ៖

- អាវកុត កតាំង ដៃវែងពណ៌កាកអំពៅស្រាល ដែលមានរូបសញ្ញាសម្គាល់ឧកញ៉ា ទំហំ២,៦ សង់ទីម៉ែត្រ គុណនឹង៣,៥សង់ទីម៉ែត្រ លើ កតាំងនៃចុងកអាវទាំងសងខាង ផែកខ្នងខាងក្រោមទាំងសងខាង និងមានឡេវមុខជារូបសញ្ញាសម្គាល់ស្រះ(ឧ)ពេញតួ ពណ៌មាសផុស ទំហំ២សង់ទីម៉ែត្រ ចំនួនប្រាំគ្រាប់។ នៅលើស្មាអាវមានខ្សែរន្ធសងខាងធ្វើពីក្រណាត់ដែលនៅម្ខាងៗមានរន្ធចំនួនពីរសម្រាប់បំពាក់សក្តិលើស្មា។ អាវនេះមានហោប៉ៅកាត់លើទ្រូងខាងឆ្វេងចំនួនមួយ ហើយនិងហោប៉ៅប៉ះមានគម្របរាងស្លឹកពោធិ៍ខាងក្រោមសងខាងចោះរន្ធដាក់ឡេវរូបសញ្ញាសម្គាល់ស្រះ(ឧ)ពេញតួ ទំហំ២សង់ទីម៉ែត្រ ពណ៌មាសផុស នៅចំកណ្តាល
- នៅលើស្មាអាវទាំងសងខាង មានបំពាក់សញ្ញាសក្តិឧកញ៉ា
- នៅចុងដៃអាវផែកទាំងសងខាងមានឡេវរូបសញ្ញាសម្គាល់ស្រះ(ឧ)ពេញតួ ទំហំ១,៥សង់ទីម៉ែត្រ ចំនួនបួនគ្រាប់ តម្រង់ជួរគ្នាលើចុងដៃអាវ
- នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់ កន្លាស់អាវ ធ្វើពីមាសផ្លាទីន១៨K។

ខ-ខោ៖

- ខោជើងវែងត្រង់ ពណ៌កាកអំពៅស្រាលដូចពណ៌អាវ
- ដេរថ្នេរបង្កប់ ចង្កេះត ក្បាលខោវែងស្រួចប្រវែង៥,៥សង់ទីម៉ែត្រ ដឹបភ្ជិខាងមុខម្ខាងមួយ និងមានហោប៉ៅចំនួនបី
- ហោប៉ៅចំហៀងពីរ មានមាត់បញ្ឆិត និងហោប៉ៅកាត់ខាងក្រោយមួយនៅផ្នែកខាងស្តាំ
- ហោប៉ៅកាត់ខាងក្រោយដេរបង្កប់ មិនមានគម្រប។

គ-ខ្សែក្រវាត់៖

- ខ្សែក្រវាត់ធ្វើអំពីស្បែកពណ៌ខៀវចាស់
- ក្បាលខ្សែក្រវាត់ធ្វើអំពីលោហធាតុលង្ហិន ឬស័ង្កសីទីតានីញ៉ូម ឬមាសផ្លាទីន១៨K ទំហំ៤,៥សង់ទីម៉ែត្រ គុណនឹង៥,៨សង់ទីម៉ែត្រ ដែលមានរូបសញ្ញាសម្គាល់ឧកញ៉ា នៅចំកណ្តាល។

ឃ-ស្បែកជើង៖

- ស្បែកជើងឃ្លុប កខ្ចី ស្បែកពណ៌ខ្មៅ
- កែងកម្ពស់៣សង់ទីម៉ែត្រ ឬកែងរាបស្មើ និងស្រោមជើងពណ៌ខ្មៅពាក់កណ្តាលស្មងជើង។

គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារឧកញ៉ាសម្រាប់បុរស មានកំណត់ក្នុងឧបសម្ព័ន្ធទី៩និងឧបសម្ព័ន្ធទី១០នៃព្រះរាជក្រឹត្យនេះ។

**២-ចំពោះស្ត្រី**

ក-អាវ៖

- អាវកបើក ដៃវែងពណ៌កាកអំពៅស្រាល មានរូបសញ្ញាសម្គាល់ឧកញ៉ា ទំហំ២,៦សង់ទីម៉ែត្រ គុណនឹង៣,៥សង់ទីម៉ែត្រ លើ កបើកនៃ កអាវទាំងសងខាង ផែកខ្នងខាងក្រោមមួយចំកណ្តាលមានជីបរាងខ្នងមកក្រោមតាមលក្ខណៈអាវស្ត្រី និងមានឡេវរូបសញ្ញាសម្គាល់ស្រៈ(ឱ)ពេញតួ ទំហំ២សង់ទីម៉ែត្រ ពណ៌មាសផុស ចំនួនបួនគ្រាប់។ នៅលើស្មាអាវមានខ្សែទ្វេសងខាងធ្វើពីក្រណាត់ដែលនៅម្ខាងៗមានរន្ធចំនួនពីរសម្រាប់បំពាក់សក្តិលើស្មា។ អាវនេះមានហោប៉ៅខាងមុខដេរបង្កប់ចំនួនពីរនៅខាងក្រោមខិតចំហៀងចំចង្កេះទាំងសងខាងដែលហោប៉ៅម្ខាងៗមានគម្របរាងស្លឹកពោធិ៍ខាងក្រោម មានឡេវរូបសញ្ញាសម្គាល់ស្រៈ(ឱ)ពេញតួ ទំហំ២សង់ទីម៉ែត្រ ពណ៌មាសផុស នៅចំកណ្តាល
- នៅលើស្មាអាវទាំងសងខាង មានបំពាក់សញ្ញាសក្តិឧកញ៉ា
- នៅចុងដៃអាវផែកទាំងសងខាងមានឡេវរូបសញ្ញាសម្គាល់ស្រៈ(ឱ)ពេញតួ ទំហំ១,៥សង់ទីម៉ែត្រ ចំនួនបីគ្រាប់ តម្រង់ជួរគ្នាលើចុងដៃអាវ
- នៅលើអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់ កន្លាស់អាវ ធ្វើពីមាសផ្លាទីន១៨K។

ខ-សំពត់បត់៖

- សំពត់បត់ពណ៌កាកអំពៅស្រាល
- សម្រុងត្រឹមភ្នែកគោរ សម្រាប់ប្រើជាមួយអាវ កបើកដៃវែង។

គ-ស្បែកជើង៖

- ស្បែកជើងកែងចោត កខ្ចី
- កែងកម្ពស់៥សង់ទីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងស្រោមជើងកខ្ចីពណ៌ខ្មៅ។

គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារឧកញ៉ាសម្រាប់ស្ត្រី មានកំណត់ក្នុងឧបសម្ព័ន្ធទី១១និងឧបសម្ព័ន្ធទី១២នៃព្រះរាជក្រឹត្យនេះ។



តេឡេក្រាម ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

## ផ្នែកទី៤
## សញ្ញាសក្តិ

**មាត្រា១៧.-**

សញ្ញាសក្តិសម្រាប់ពាក់លើឯកសណ្ឋានផ្លូវការរបស់គោរមងារលោកអ្នកឧកញ៉ាអ្នកឧកញ៉ា និងឧកញ៉ា រួមមាន៣(បី)លំដាប់ថ្នាក់ ដូចខាងក្រោម៖

១-សញ្ញាសក្តិស្មាលោកអ្នកឧកញ៉ា៖

- មានទំហំ៦សង់ទីម៉ែត្រ គុណនឹង១៣សង់ទីម៉ែត្រ នៅតាមជាយមានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញសក្តិដោយផ្ទៃពណ៌ដីលែង
- មានរូបព្រះរាជសង្ហាមួយពណ៌មាសនៅចំពីលើកំពូលចុងសក្តិ និងគ្រាប់រង្វង់បង្គប់ដោយសញ្ញាសម្គាល់ឧកញ៉ា ពណ៌មាសផុស ចំនួនបីគ្រាប់នៅចំកណ្តាលផ្តើមចេញពីទំហំតូច មធ្យម និងធំ បន្តពីរូបព្រះរាជសង្ហា
- នៅពីក្រោមគ្រាប់រង្វង់ទំហំធំមានសរសេរអក្សរថាលោកអ្នកឧកញ៉ា ពណ៌មាសទ្រពីក្រោមដោយក្បាច់ភ្ញីទេសពណ៌មាសសម្រាប់សម្គាល់គោរមងារលោកអ្នកឧកញ៉ា ដែលជាលំដាប់ថ្នាក់ទី១។

គំរូសញ្ញាសក្តិស្មាលោកអ្នកឧញ៉ា មានកំណត់ក្នុងឧបសម្ព័ន្ធទី១៣នៃព្រះរាជក្រឹត្យនេះ។

២-សញ្ញាសក្តិស្មាអ្នកឧកញ៉ា៖

- មានទំហំ៦សង់ទីម៉ែត្រ គុណនឹង១៣សង់ទីម៉ែត្រ នៅតាមជាយមានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញសក្តិដោយផ្ទៃពណ៌បៃតង
- មានរូបព្រះរាជសង្ហាមួយពណ៌មាសនៅចំពីលើកំពូលចុងសក្តិ និងគ្រាប់រង្វង់បង្គប់ដោយសញ្ញាសម្គាល់ឧកញ៉ា ពណ៌មាសផុស ចំនួនពីរគ្រាប់នៅចំកណ្តាលផ្តើមចេញពីទំហំតូចនិងធំ បន្តពីរូបព្រះរាជសង្ហា។
- នៅពីក្រោមគ្រាប់រង្វង់ទំហំធំមានសរសេរអក្សរថាអ្នកឧកញ៉ា ពណ៌មាសទ្រពីក្រោមដោយក្បាច់ភ្ញីទេសពណ៌មាស សម្រាប់សម្គាល់គោរមងារអ្នកឧកញ៉ា ដែលជាលំដាប់ថ្នាក់ទី២។

គំរូសញ្ញាសក្តិស្មាអ្នកឧញ៉ា មានកំណត់ក្នុងឧបសម្ព័ន្ធទី១៤នៃព្រះរាជក្រឹត្យនេះ។

៣-សញ្ញាសក្តិស្មាឧកញ៉ា៖

- មានទំហំ៦សង់ទីម៉ែត្រ គុណនឹង១៣សង់ទីម៉ែត្រ នៅតាមជាយមានក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញសក្តិដោយផ្ទៃពណ៌ទឹកប៊ិច
- មានរូបព្រះរាជសង្ហាមួយពណ៌មាសនៅចំពីលើកំពូលចុងសក្តិ និងគ្រាប់រង្វង់បង្គប់ដោយសញ្ញាសម្គាល់ឧកញ៉ា ពណ៌មាសផុស ចំនួនមួយគ្រាប់នៅចំកណ្តាលបន្តពីរូបព្រះរាជសង្ហា
- នៅពីក្រោមគ្រាប់រង្វង់មានសរសេរអក្សរថាឧកញ៉ាពណ៌មាសទ្រពីក្រោមដោយក្បាច់ភ្ញីទេសពណ៌មាសសម្រាប់សម្គាល់គោរមងារឧកញ៉ា ដែលជាលំដាប់ថ្នាក់ទី៣។

គំរូសញ្ញាសក្តិស្មាឧកញ៉ា មានកំណត់ក្នុងឧបសម្ព័ន្ធទី១៥នៃព្រះរាជក្រឹត្យនេះ។

## ផ្នែកទី៥
## សញ្ញាសម្គាល់

**មាត្រា១៨.-**

សញ្ញាសម្គាល់ចុងកអាវ ចុងដៃអាវ គ្រាប់ឡេវ និងកន្លាស់អាវ សម្រាប់ពាក់លើឯកសណ្ឋានផ្លូវការរបស់គោរមងារលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា មានដូចខាងក្រោម៖

**១-សញ្ញាសម្គាល់ចុងកអាវ**

សញ្ញាសម្គាល់ចុងកអាវ កតាំងសម្រាប់បុរស និងចុងកអាវ កបើកសម្រាប់ស្ត្រី ជារូបសញ្ញាសម្គាល់ ឧកញ៉ា ដែលមានរូបរំលេចចេញជាស្រះ(ឧ)ពេញតួ មានក្បាលស្រះជារូបក្បាលហង្ស ហើយតួស្រះពត់ពេន ដោយក្បាច់ភ្ញីទេសពណ៌មាស ព័ទ្ធជុំវិញដោយក្បាច់ភ្ញីទេសពណ៌មាស រាងជាស្លឹកពោធិ៍ទំហំខ្នាត២,៦ សង់ទីម៉ែត្រ គុណនឹង៣,៥សង់ទីម៉ែត្រ។

**២-សញ្ញាសម្គាល់ចុងដៃអាវ**

សញ្ញាសម្គាល់ចុងដៃអាវ មានគ្រាប់ឡេវជារង្វង់ មានស្រះ(ឧ)ពេញតួ ទំហំ១,៥សង់ទីម៉ែត្របញ្ឈរ ជាជួរត្រង់គ្នាចំនួនបួនគ្រាប់សម្រាប់បុរស និងចំនួនបីគ្រាប់សម្រាប់ស្ត្រី ដែលមានក្បាលស្រះជារូបក្បាលហង្ស ហើយតួស្រះពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាសផុស នៅចំកណ្ដាលផ្ទៃរង្វង់ឡេវពណ៌មាស។

**៣-សញ្ញាសម្គាល់គ្រាប់ឡេវ**

គ្រាប់ឡេវមានរាងជារង្វង់មានស្រះ(ឧ)ពេញតួនៅចំកណ្ដាល ដែលមានក្បាលស្រះជារូបក្បាលហង្ស ហើយតួស្រះពត់ពេនដោយក្បាច់ភ្ញីទេសពណ៌មាសផុសនៅចំកណ្ដាលផ្ទៃរង្វង់ឡេវពណ៌មាស។ គ្រាប់ឡេវត្រូវបានបែងចែកជាពីរខ្នាត ដែលមានទំហំអង្កត់ផ្ចិតដូចខាងក្រោម៖

- គ្រាប់តូចទំហំ១,៥សង់ទីម៉ែត្រ
- គ្រាប់ធំទំហំ២សង់ទីម៉ែត្រ។

**៤-សញ្ញាសម្គាល់កន្ទាស់អាវ**

កន្ទាស់អាវ មានសញ្ញាសម្គាល់ដូចខាងក្រោម៖

- រូបក្បាលហង្សពណ៌មាសរាងក្បាលស្រះ(ឧ)ពេញតួ
- ក្បាច់ភ្ញីទេសពណ៌មាសពត់ពេនជារាងស្រះ(ឧ)ពេញតួ
- ក្បាច់ភ្ញីទេសពណ៌មាសដែលមានរូបរាងដូចស្លឹកពោធិ៍ព័ទ្ធពីក្រៅជុំវិញស្រះ(ឧ)ពេញតួ
- ក្បាច់ត្របកឈូកធំពណ៌មាសដែលនៅចំកណ្ដាលពីខាងក្រោមនៃស្រះ(ឧ)ពេញតួ និងក្បាច់ត្របកឈូកតូចៗពណ៌មាសជាច្រើនព័ទ្ធជុំវិញតាមរាងស្លឹកពោធិ៍
- ខ្សែបូពណ៌មាសទ្រពីក្រោមរូបស្លឹកពោធិ៍ មានចារឹកអក្សរខ្មែរពណ៌មាសសមាគមឧកញ៉ាកម្ពុជា
- ក្បាច់ភ្ញីទេសពណ៌មាសទ្រពីក្រោមខ្សែបូ។

គំរូសញ្ញាសម្គាល់ចុងកអាវ ចុងដៃអាវ គ្រាប់ឡេវ និងកន្ទាស់អាវ សម្រាប់គោរមងារលោកអ្នកឧញ៉ា អ្នកឧកញ៉ា និងឧកញ៉ា មានកំណត់ក្នុងឧបសម្ព័ន្ធទី១៣ ឧបសម្ព័ន្ធទី១៤ និងឧបសម្ព័ន្ធទី១៥នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៧
## សមាគមឧកញ៉ាកម្ពុជា

**មាត្រា១៩ .-**

សមាគមឧកញ៉ាកម្ពុជាដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានទទួលស្គាល់ជាដៃគូរបស់រាជរដ្ឋាភិបាលលើការងារដូចខាងក្រោម៖

- ជាស្ថាប័នតែមួយគត់ដែលតំណាងឱ្យគោរមងារទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ជួយរាជរដ្ឋាភិបាលលើការពិនិត្យនិងវាយតម្លៃចំពោះសំណើសុំផ្ដល់គោរមងារឧកញ៉ា ស្របតាមព្រះរាជក្រឹត្យនេះ



តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

- ជួយរាជរដ្ឋាភិបាលលើការប្រមូលវិភាគទានពីគោរមវន្ត អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ជួយរាជរដ្ឋាភិបាលលើការធ្វើបច្ចុប្បន្នកម្មបញ្ជីឈ្មោះ និងរៀបចំចាត់ថែងឯកសណ្ឋានផ្លូវការរបស់គោរមវន្តទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា
- ជួយរាជរដ្ឋាភិបាលលើការពិនិត្យសំណើសុំផ្តល់ងារជាកិត្តិយស បុព្វសិទ្ធិនានា ឬការតែងតាំងក្នុងមុខងារនានាដល់គោរមវន្ត ស្របតាមមាត្រា២១នៃព្រះរាជក្រឹត្យនេះ
- ជាដៃគូរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញលើកកម្ពស់សេដ្ឋកិច្ច សកម្មភាពពាណិជ្ជកម្ម និងការវិនិយោគ ព្រមទាំងសកម្មភាពផ្សេងទៀត ដើម្បីប្រយោជន៍ដល់សង្គម
- អមដំណើរជាមួយនាយករដ្ឋមន្ត្រីក្នុងបេសកកម្មមួយចំនួនទាំងក្នុងនិងក្រៅប្រទេស តាមការអនុញ្ញាតរបស់នាយករដ្ឋមន្ត្រី សំដៅជំរុញលើកកម្ពស់ការធ្វើពាណិជ្ជកម្មនិងវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២០ .-**

រូបសញ្ញានៃសមាគមឧកញ៉ាកម្ពុជាមានលក្ខណៈសម្គាល់ដូចខាងក្រោម៖

- រូបក្បាលហង្សពណ៌មាសរាងក្បាលស្រះ(ន)ពេញតួ
- ក្បាច់ភ្ញីទេសពណ៌មាសពត់ពេនជារាងស្រះ(ន)ពេញតួ
- ក្បាច់ភ្ញីទេសពណ៌មាសដែលមានរូបរាងដូចស្លឹកពោធិ៍ព័ទ្ធពីក្រៅជុំវិញស្រះ(ន)ពេញតួ
- ក្បាច់គ្របកណ្តុកធំពណ៌មាសដែលនៅចំកណ្តាលពីខាងក្រោមនៃស្រះ(ន) ពេញតួ និងក្បាច់គ្របកណ្តុកតូចៗពណ៌មាសជាច្រើនព័ទ្ធជុំវិញតាមរាងស្លឹកពោធិ៍
- ខ្សែបូរពណ៌មាសទ្រពីក្រោមរូបស្លឹកពោធិ៍មានចារឹកអក្សរខ្មែរពណ៌មាស សមាគមឧកញ៉ាកម្ពុជា
- ក្បាច់ភ្ញីទេសពណ៌មាសទ្រពីក្រោមខ្សែបូរ។

គំរូរូបសញ្ញានៃសមាគមឧកញ៉ាកម្ពុជា មានកំណត់ក្នុងឧបសម្ព័ន្ធទី១៦នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៤

## សិទ្ធិនិងភារកិច្ចរបស់លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា

**មាត្រា២១ .-**

លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា មានសិទ្ធិនិងភារកិច្ចដូចខាងក្រោម៖

- ទទួលបាននូវការផ្តល់ងារជាកិត្តិយស បុព្វសិទ្ធិនានា ឬការតែងតាំងក្នុងមុខងារដែលមិនត្រូវបានហាមឃាត់ក្នុងព្រះរាជក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- អាចលើកសំណូមពរឬសំណើផ្សេងៗ តាមរយៈសមាគមឧកញ៉ាកម្ពុជា មករាជរដ្ឋាភិបាលដើម្បីពិនិត្យនិងដោះស្រាយ
- ចូលរួមថែរក្សា ការពារវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ដ៏ល្អរបស់ជាតិ
- បង់វិភាគទានប្រចាំឆ្នាំ ដើម្បីចូលរួមចំណែកកសាងនិងអភិវឌ្ឍប្រទេសជាតិ លើកលែងតែគោរមវន្តដែលមានចំណេះជំនាញពិសេសលើវិស័យណាមួយ ហើយមានការទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចជាតិឬអន្តរជាតិ
- ចូលរួមចំណែកកសាងនិងអភិវឌ្ឍប្រទេសជាតិតាមការអំពាវនាវឬសំណូមពររបស់រាជរដ្ឋាភិបាល
- ចូលរួមលើកកម្ពស់ការគោរពសិទ្ធិមនុស្សនិងការងារមនុស្សធម៌ក្នុងសង្គមជាតិ។

ចំនួនថវិកាត្រូវបង់វិភាគទានប្រចាំឆ្នាំ ដើម្បីចូលរួមចំណែកកសាងនិងអភិវឌ្ឍប្រទេសជាតិរបស់លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២២.-**

លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ត្រូវគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់នូវសីលធម៌ល្អ ប្រកបមុខរបរស្របច្បាប់ និងចៀសវាងសកម្មភាពណាដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់គោរមងារឧកញ៉ា។

## ជំពូកទី៩
## ការបញ្ចប់គោរមងារឧកញ៉ា

**មាត្រា២៣.-**

គោរមងារឧកញ៉ាអាចត្រូវបានបញ្ចប់ ក្នុងករណីណាមួយដូចខាងក្រោម៖

- គោរមវន្តសុំលាលែងពីគោរមងារឧកញ៉ាដោយស្ម័គ្រចិត្ត
- គោរមវន្តមិនបំពេញកាតព្វកិច្ចបង់វិភាគទានប្រចាំឆ្នាំរយៈពេល៣(បី)ឆ្នាំជាប់គ្នា ដោយគ្មានមូលហេតុ
- គោរមវន្តត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ
- ត្រូវបានរកឃើញថាគោរមវន្តបានប្រព្រឹត្តល្មើសនឹងមាត្រា២២នៃព្រះរាជក្រឹត្យនេះ
- ត្រូវបានរកឃើញថាសំណុំឯកសារស្នើសុំគោរមងារឧកញ៉ារបស់គោរមវន្តមានការក្លែងបន្លំ។

បែបបទនិងនីតិវិធីនៃការបញ្ចប់គោរមងារឧកញ៉ា ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១០
## អន្តរប្បញ្ញត្តិ

**មាត្រា២៤.-**

ព្រះរាជក្រឹត្យនេះមិនមានអានុភាពប្រតិសកម្មដល់គោរមងារឧកញ៉ាដែលគោរមវន្តទទួលបានមុនពេលព្រះរាជក្រឹត្យនេះចូលជាធរមានឡើយ។

គោរមវន្តទាំងអស់ត្រូវអនុវត្តសិទ្ធិនិងកាតព្វកិច្ចដែលកំណត់ក្នុងព្រះរាជក្រឹត្យនេះ។

មន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន ដែលកំពុងបំពេញការងារតាមក្រសួង ស្ថាប័ននានារបស់រដ្ឋ ដែលទទួលបានគោរមងារឧកញ៉ាមុនព្រះរាជក្រឹត្យនេះចូលជាធរមាន ត្រូវស្នើសុំឈប់ប្រើប្រាស់គោរមងារឧកញ៉ា ឬឈប់ពីក្របខណ្ឌមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន ក្នុងរយៈពេលយ៉ាងយូរ៦(ប្រាំមួយ)ខែ បន្ទាប់ពីព្រះរាជក្រឹត្យនេះចូលជាធរមាន។

បទប្បញ្ញត្តិក្នុងកថាខណ្ឌទី៣ខាងលើ មិនអនុវត្តចំពោះគោរមវន្តដែលមានចំណេះជំនាញពិសេសលើវិស័យណាមួយ ហើយមានការទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចជាតិឬអន្តរជាតិ។

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា២៥.-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៧៣២ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីគោរមងារឧកញ៉ា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

**មាត្រា២៦.-**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ ពុធ ១២ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០២៣

**នរោត្តម សីហមុនី**

ពស.២៣១០.២៣៦៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ចេវ៉ូ ចិតស្រុត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ចេវ៉ូ ចិតស្រុត**

## ឧបសម្ព័ន្ធទី១នៃព្រះរាជក្រឹត្យស្តីពីគោរមងារឧកញ៉ា
## គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារ លោកអ្នកឧកញ៉ា

### ១-ចំពោះបុរស

**អាវកុត ក្រវ៉ាត់ និងខោ**



អាវពីមុខ



អាវពីក្រោយ



ខ្សែក្រវ៉ាត់បុរស



ស្បែកជើងបុរស



ខោពីមុខ



ខោពីក្រោយ



ស្រោមជើង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL



តេឡេក្រាម ឯកសារផ្លូវការណ៍: - https://t.me/oa_channel

## ឧបសម្ព័ន្ធទី២នៃព្រះរាជក្រឹត្យស្ដីពីគោរមងារឧកញ៉ា
## គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារ លោកអ្នកឧកញ៉ា

### ១. ចំពោះមុខ




ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ឧបសម្ព័ន្ធទី៣នៃព្រះរាជក្រឹត្យស្ដីពីគោរមងារឧកញ៉ា
## គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារ លោកអ្នកឧកញ៉ា

២-ចំពោះស្ត្រី

### អាវកបើក និងសំពត់បត់ឆ្វេង


អាវពីមុខ


អាវពីក្រោយ


ស្បែកជើងខ្មៅ


សំពត់ពីមុខ


សំពត់ពីក្រោយ


ស្រោមជើង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



https://t.me/oa_channel

**ឧបសម្ព័ន្ធទី៤នៃព្រះរាជក្រឹត្យស្ដីពីគោរមងារឧកញ៉ា**
**ទំរង់ឯកសណ្ឋានផ្លូវការរបស់គោរមងារ លោកអ្នកឧកញ៉ា**

២. ចំពោះស្ត្រី




ROYAUME DU CAMBODGE * TRONE *
LE MINISTRE DU PALAIS ROYAL

## ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យស្ដីពីគោរមងារឧកញ៉ា
## គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារ អ្នកឧកញ៉ា

### ១-ចំពោះបុរស

**អាវក្រុក ក្រវាត់ និងខោ**



អាវពីមុខ



អាវពីក្រោយ



ខ្សែក្រវាត់បុរស



ស្បែកជើងបុរស



ខោពីមុខ



ខោពីក្រោយ



ស្រោមជើង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

## ឧបសម្ព័ន្ធទី៦នៃព្រះរាជក្រឹត្យស្ដីពីគោរមងារឧកញ៉ា
## គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារ អ្នកឧកញ៉ា

### ១. ចំពោះបុរស




ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ឧបសម្ព័ន្ធទី៧នៃព្រះរាជក្រឹត្យស្ដីពីគោរមងារឧកញ៉ា
## គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារ អ្នកឧកញ៉ា

**២-ចំពោះស្ត្រី**

**អាវកបើក និងសំពត់បត់ជែង**



អាវពីមុខ



អាវពីក្រោយ



ស្បែកជើងខ្មៅ



សំពត់ពីមុខ



សំពត់ពីក្រោយ



ស្រោមជើង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



https://t.me/oa_channel

## ឧបសម្ព័ន្ធទី៨ នៃព្រះរាជក្រឹត្យស្ដីពីគោរមងារឧកញ៉ា
## គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារ អ្នកឧកញ៉ា

២. ចំពោះស្ត្រី




ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ឧបសម្ព័ន្ធទី៥នៃព្រះរាជក្រឹត្យស្តីពីគោរមងារឧកញ៉ា
## គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារ ឧកញ៉ា

### ១-ចំពោះបុរស

#### អាវកុត កកាំង និងខោ


អាវពីមុខ


អាវពីក្រោយ


ខ្សែក្រវាត់បុរស


ស្បែកជើងបុរស


ខោពីមុខ


ខោពីក្រោយ


ស្រោមជើង



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គេឡើក្រោម ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

## ឧបសម្ព័ន្ធទី១០នៃព្រះរាជក្រឹត្យស្ដីពីគោរមងារឧកញ៉ា
## គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារ ឧកញ៉ា

១. ចំពោះបុរស




ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ឧបសម្ព័ន្ធទី១១នៃព្រះរាជក្រឹត្យស្ដីពីគោរមងារឧកញ៉ា
## គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារ ឧកញ៉ា

### ២-ចំពោះស្ត្រី

**ឈុតក្រើក និងសំពត់បត់ខែន**






ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

https://t.me/oa_channel

**ឧបសម្ព័ន្ធទី១២នៃព្រះរាជក្រឹត្យស្តីពីគោរមងារឧកញ៉ា**
**គំរូឯកសណ្ឋានផ្លូវការរបស់គោរមងារ ឧកញ៉ា**

**២. ចំពោះស្ត្រី**






ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ឧបសម្ព័ន្ធទី១៣នៃព្រះរាជក្រឹត្យស្តីពីគោរមងារឧកញ៉ា
## គំរូនិងទំហំខ្នាត សញ្ញាស័ក្តិ សញ្ញាសម្គាល់ គ្រាប់ឡេវ និងខ្សែក្រវាត់ លោកអ្នកឧកញ៉ា




សញ្ញាស័ក្តិលើស្មា




សញ្ញាសម្គាល់លើ កពាំង




សញ្ញាសម្គាល់កន្លាស់អាវ




គ្រាប់ឡេវបើតួអាវ




គ្រាប់ឡេវចុងដៃអាវ




ក្បាលខ្សែក្រវាត់




ក្បាលខ្សែក្រវាត់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

https://t.me/oa_channel

**ឧបសម្ព័ន្ធទី១៤នៃព្រះរាជក្រឹត្យស្តីពីគោរមងារឧកញ៉ា**
**គំរូនិងទំហំខ្នាត សញ្ញាស័ក្តិ សញ្ញាសម្គាល់ គ្រាប់ឡេវ និងខ្សែក្រវាត់ អ្នកឧកញ៉ា**




សញ្ញាស័ក្តិលើស្មា




សញ្ញាសម្គាល់លើ កតាំង




សញ្ញាសម្គាល់ខ្ទាស់អាវ




គ្រាប់ឡេវលើអាវ




គ្រាប់ឡេវចុងដៃអាវ




ក្បាលខ្សែក្រវាត់




ក្បាលខ្សែក្រវាត់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធទី១៦នៃព្រះរាជក្រឹត្យស្តីពីគោរមងារឧកញ៉ា
និមិត្តសញ្ញានៃសមាគមឧកញ៉ាកម្ពុជា

[illegible]

[illegible]

[illegible]



[illegible]

[illegible]

[illegible]



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

https://t.me/oa_channel

## ឧបសម្ព័ន្ធទី១៥នៃព្រះរាជក្រឹត្យស្តីពីគោរមងារឧកញ៉ា
## គំរូនិងទំហំខ្នាត សញ្ញាស័ក្តិ សញ្ញាសម្គាល់ គ្រាប់ឡេវ និងខ្សែក្រវាត់ ឧកញ៉ា




សញ្ញាស័ក្តិលើស្មា




សញ្ញាសម្គាល់លើ កតាំង




សញ្ញាសម្គាល់កខ្លាស់អាវ




គ្រាប់ឡេវលើតួអាវ



គ្រាប់ឡេវចុងដៃអាវ




ក្បាលខ្សែក្រវាត់



ក្បាលខ្សែក្រវាត់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL